**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

លេខៈ......១៥៧៩......អ គ រ

# សេចក្តីជូនដំណឹង

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អគរ**) សូមជម្រាបជូនដំណឹងដល់សាធារណជនដែលជាម្ចាស់យានយន្តគ្មានពន្ធគ្រប់ប្រភេទ ដែលមិនទាន់បានចូលមកបង់ពន្ធនិងអាករដោយស្ម័គ្រចិត្ត ឲ្យបានជ្រាបថា ការទទួលបង់ពន្ធអាករយានយន្តក្នុងដំណាក់កាលអនុគ្រោះលើប្រាក់ពិន័យ បានឈានកាន់តែកៀកជិតដល់ពេលបញ្ចប់ហើយ ដែលបន្ទាប់ពីនោះ គឺជាដំណាក់កាលនៃប្រតិបត្តិការបង្ក្រាប និងបង្ខំឲ្យបង់ពន្ធ អាករ និងប្រាក់ពិន័យ ដោយពុំមានការអនុគ្រោះបន្តទៀតឡើយ។

ទន្ទឹមនេះ **អគរ** សូមលើកឡើងនូវបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធជាធរមានមួយចំនួន ដែលម្ចាស់យានយន្តគ្មានពន្ធនានាត្រូវស្វែងយល់ ដូចខាងក្រោម÷

១. **ច្បាប់ស្តីពីគយ មាត្រា៥** “ទំនិញនាំចេញ ឬនាំចូលទាំងអស់ គឺជាកម្មវត្ថុនៃការអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ។ ទំនិញទាំងឡាយដែលចូលមកក្នុង ឬ ចេញពីដែនគយ ត្រូវជាប់ពន្ធនាំចូល ឬ នាំចេញ និងអាករ ដូចមានចែងក្នុងតារាងពន្ធគយ។” ....

២. **ច្បាប់ស្តីពីគយ មាត្រា៧២** “បុគ្គលណាដែលនាំចេញ ឬ នាំចូល ឬ ប៉ុនប៉ងនាំចេញ ឬ ប៉ុនប៉ងនាំចូលទំនិញដោយរំលោភបំពានលើច្បាប់ ឬ បញ្ញត្តិនានា ត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើស។ បុគ្គលណាដែលប្រព្រឹត្តបទល្មើសគយ ត្រូវផ្តន្ទាទោសពិន័យរដ្ឋបាលដែលកំណត់ដោយរដ្ឋបាលគយ និងទោសទណ្ឌតាមផ្លូវតុលាការដែលកំណត់ដោយតុលាការមានសមត្ថកិច្ច ឬ ទោសណាមួយនៃទោសទាំងពីរ។”

៣. **ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក មាត្រា៧៨** “ជនណាដែលចរាចរយានជំនិះ ដោយប្រើប្រាស់បណ្ណបើកបរ បណ្ណសម្គាល់យានជំនិះ ផ្លាកលេខសម្គាល់យានជំនិះ ឬលិខិតអនុញ្ញាតផ្សេងៗដោយដឹងថាជាឯកសារឬវត្ថុក្លែងក្លាយ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦៣០ (បទប្រើប្រាស់ឯកសារសាធារណៈក្លែង) នៃក្រមព្រហ្មទណ្ឌ។”

៤. **ក្រមព្រហ្មទណ្ឌ មាត្រា៦៣០** “បទប្រើប្រាស់ឯកសារសាធារណៈក្លែង- ការប្រើប្រាស់ឯកសារក្លែងដែលមានចែងក្នុងមាត្រា ៦២៩ (បទក្លែងបន្លំ ឯកសារសាធារណៈ) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។”

អាស្រ័យហេតុនេះ **អគរ** សូមធ្វើការក្រើនរំឭកជាចុងក្រោយ ដល់ម្ចាស់យានយន្តគ្មានពន្ធទាំងអស់ ឲ្យរួសរាន់ចូលមកបង់ពន្ធនិងអាករឲ្យបានឆាប់បំផុត ដើម្បីឲ្យទាន់ដំណាក់កាលអនុគ្រោះនេះ។ **អគរ** សូមបញ្ជាក់ថា វិធានការចាប់បង្ក្រាបយានយន្តគ្មានពន្ធ ត្រូវអនុវត្តដោយម៉ឺងម៉ាត់បំផុត និងទូលំទូលាយនៅទូទាំងប្រទេស ដោយពុំមានការអនុគ្រោះ ឬរើសអើងឡើយ។

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥

អាសយដ្ឋានៈ លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ/ទូរសារៈ (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៥៧ / E-mail: info-pru@customs.gov.kh